ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងការពារជាតិមានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា នៅរសៀលថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥ **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ សីហា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា** បានជួបពិភាក្សាជាមួយ **ឯកឧត្តម** Phumtham Wechayachai **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រថៃ** អំពីភាពតានតឹងនៅតាមបណ្តោយព្រំដែនប្រទេសទាំងពីរ ដែលបានប្រព្រឹត្តិទៅនៅស្រុកអារញ្ញប្រថេត ខេត្តស្រះកែវ ព្រះរាជាណាចក្រថៃ ដោយមានខ្លឹមសារសំខាន់ៗដូចខាងក្រោម៖

ភាគីទាំងពីរបានឯកភាពគ្នាប្រឹងប្រែងឱ្យអស់ពីលទ្ធភាពដើម្បីរក្សាសន្តិភាព សន្តិសុខ និងស្ថិរភាពតាមបណ្តោយព្រំដែន ជាពិសេសតំបន់ដែលកំពុងមានភាពតានតឹង តាមរយៈការរក្សាការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ការយោគយល់គ្នា និងការសន្ទនាប្រកបដោយសន្តិវិធី ក្នុងគោលបំណងជៀសវាងការប៉ះទង្គិចយោធា ដែលភាគីទាំងសងខាងសុទ្ធតែមិនចង់ឃើញ។

នៅក្នុងជំនួបនោះ ភាគីថៃក៏បានស្នើសុំឱ្យភាគីកម្ពុជាដកកងទ័ពចេញ ពីទីតាំងឈរជើងនៅតំបន់មុំបី ដែលបានប្រយុទ្ធគ្នាកាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ កន្លងទៅ ភាគីកម្ពុជាបានបដិសេធមិនទទួលការស្នើសុំនេះទេ ព្រោះទីតាំងខាងលើជាទីតាំងស្ថិតក្នុងដែនអធិបតេយ្យភាពរបស់កម្ពុជា ដែលបានឈរជើងជាអចិន្ត្រៃយ៍តាំងពីដើមរៀងមក។ ភាគីកម្ពុជាមិនអាចថយពីទីតាំង ដែលកងទ័ពកម្ពុជាបានឈរជើងជាយូរណាស់មកហើយ និងដែលស្ថិតក្នុងដែនអធិបតេយ្យភាពរបស់កម្ពុជាបានឡើយ។

ភាគីកម្ពុជាក៏បានបញ្ជាក់ផងដែរថា ដរាបណាភាគីថៃនៅតែប្រើប្រាស់ផែនទីខុសគ្នា និងមាត្រដ្ឋានខុសគ្នា នោះយើងនឹងមិនអាចស្វែងរកចំនុចរួម ក្នុងការថែរក្សាស្ថិរភាពព្រំដែនបានឡើយ។ ភាគីកម្ពុជានៅតែប្រកាន់ស្មារតី គោរពអនុស្សរណៈ នៃការយោគយល់គ្នាឆ្នាំ២០០០ (MOU 2000) រវាងប្រទេសទាំងពីរ ដូចដែលមានកន្លងមក។

ក្នុងន័យនេះ ភាគីកម្ពុជាបានសម្រេចចិត្តរៀបចំសំណុំរឿងបញ្ជូនវិវាទតំបន់ទាំង៤ រួមមាន តំបន់មុំបី ប្រាសាទតាមាន់ធំ ប្រាសាទតាមាន់តូច និងប្រាសាទតាក្របី ទៅតុលាការយុត្តិធម៌អន្តរជាតិ(ICJ) នៅទីក្រុងឡាអេ ដើម្បីផ្តល់ភាពច្បាស់លាស់ដល់ព្រំដែននៃប្រទេសទាំងពីរ និងការពារកុំឱ្យបញ្ហាទាំងនេះក្លាយទៅជាជម្លោះធ្ងន់ធ្ងរទៅថ្ងៃអនាគត តាមរយៈដំណោះស្រាយមួយដែលយុត្តិធម៌ និងមិនលម្អៀង ព្រមទាំងផ្អែកលើច្បាប់អន្តរជាតិ។ ការសម្រេចចិត្តនេះបានបង្ហាញយ៉ាងច្បាស់ការប្តេជ្ញាចិត្តរបស់ភាគីកម្ពុជា ក្នុងការដោះស្រាយជម្លោះដោយសន្តិវិធី និងផ្អែកលើច្បាប់អន្តរជាតិ ដើម្បីធានាថាព្រំដែនរវាងប្រទេសទាំងពីរនៅតែជាព្រំដែនសន្តិភាព ស្ថិរភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ។ ជាមួយគ្នានេះ ភាគីកម្ពុជាក៏នឹងបន្តប្រើប្រាស់យន្តការដែលមានស្រាប់ ដូចជា GBC/JBC/RBC ដើម្បីពិភាក្សាលើចំនុចដទៃទៀតនាថ្ងៃខាងមុខ។

ជាការឆ្លើយតប ភាគីថៃក៏បានបង្ហាញពីការគោរពសិទ្ធិរបស់កម្ពុជា ក្នុងការដាក់ចំនុចទាំង៤ខាងលើទៅតុលាការយុត្តិធម៌អន្តរជាតិ(ICJ) ។ លើសពីនេះ ភាគីថៃក៏បានបញ្ជាក់ និងច្រានចោលរាល់ព័ត៌មានអុចអាល និងរុញច្រានស្ថានការណ៍ ដែលបានធ្វើឱ្យប៉ះពាល់សតិអារម្មណ៍កងទ័ព និងប្រជាជននៃប្រទេសទាំងពីរ ព្រមទាំងបញ្ឈប់ការបញ្ឆេះកំហឹងជាតិសាសន៍ ដូចជាការលើកឡើងពីការបិទច្រកព្រំដែនអន្តរជាតិ ការលុបកិច្ចប្រជុំJBC និងព័ត៌មានដែលគ្មានប្រភពច្បាស់លាស់។

ថ្ងៃសុក្រ១១កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ,ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៥

វិថីហ្សកនឹមឹត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ : ០២៣ ៨៨៣ ២៧៤ អ៊ីមែល generalsec@mod.gov.kh